# រឿង មហាចោរនៅទល់ដែន

**ភាគទី១៨**

ព្រះអរុណថ្ងៃនេះរះឡើងយ៉ាងត្រចះត្រចង់។ ប្រជាជនគ្រប់រូបភ្ញាក់ពីព្រលឹមខុសពីធម្មតា ។ ម្នាក់ៗ សំរេចចិត្តចាំមើលក្បួនទ័ពមានមានន្ទដែលវិលត្រលប់ពីច្បាំង។ យើងរាល់គ្នាស្លៀកល្អ ពាក់ល្អ ឈរកុះករនៅនឹងផ្សារ។ មិនយូរប៉ុន្មានក្បួនទ័ពមកដល់។

ដំបូងគេឮស្គរជ័យយ៉ាងអឺកធឹក ។ បន្តិចក្រោយមកអង្គទ័ពមកដល់។ ទាហានដើរជាជួរសម្បើមដោយអាវុធដែលកាន់គ្រប់ៗដៃ គឺមានខែល លំពែង ស្នា ព្រួញ ដាវជាដើម។ ពលរេហ៍ដើរកក្រើកផែនដី។ បន្ទាប់មកគឺទ័ពសេះដែលសង្ហាជាងគេ ។ ម្នាក់ៗ អង្គុយលើខ្នងអាជានេយ្យ ត្រង់ខ្លួនគ្មានងាកទៅណាឡើយ ។ ដាវដែលព្យួរនៅចង្កេះឃើញគួរស្ញើប។ ក្រោយមកទៀត មានទ័ពខាងដំរីដែលតុបតែងដោយគ្រឿងអលង្ការនៅក្លុក នៅលើក្បាលនិងទៅលើខ្នង មើលឃើញរុងរឿងបីដូចក្នុងរឿងមួយពាន់មួយយប់។ នៅលើខ្នងដំរីនេះ អ្នកឈរមើលពលរេហ៍ គឺមាននន្ទមេទ័ព។

មាននន្ទឈរផ្ទឹង ដាវដែលហូតហើយ ដែលកាន់នៅដៃនោះមានរស្មីចាំងនឹងព្រះអាទិត្យភ្លឺព្រាតៗ ។ ដោយគ្រឿងសម្លៀកបំពាក់ ដោយមាឌមាំ វីរបុរសហាក់មានអំណាចឥតឧបមា។ មាននន្ទនាំទ័ពដែលមានចំនួនប្រមាណប្រាំពាន់នាក់ ។ រួចគេឮសូរសម្រែកយ៉ាងខ្លាំង បញ្ជាឲ្យពលរេហ៍ឈប់។ តាមរបងប្រជាជន ក្មេង ចាស់ ប្រុស ស្រី ដែលឈរមើលក៏បន្លឺនូវសម្រែកថាជយោលាន់ឮរំពងឡើង។ ឱ! តាំងពីកាលណាមក ពុំដែលមានព្រឹត្តិការណ៍ដ៏រីករាយដូច្នោះទេ ក្នុងអាណាខេត្តសេរីសោភ័ណយើង។ មនុស្សម្នាក់ៗ សប្បាយគ្រប់ៗគ្នា។ អ្នកលក់ដូរក៏ចេញទៅលក់ព្រោងព្រាត ។ អ្នកដើរមើលក្បួនទ័ពក៏ច្រើន ណែនណាន់តាន់តាប់ ដើរចុះឡើងប្រជ្រៀតប្រជែងគ្នា។ ទ័ពក៏ហែព័ទ្ធជុំវិញបន្ទាយព្រះកម្ពុត ចំនួនបីជុំ ឆាកហោជយោលាន់ឮរណ្ដំគ្នាអឺងកង ។ ភ្លេង និង ស្គរឲ្យចង្វាក់ដល់ទាហានដែលដើរ។ ក្មេងៗរត់តាមមើលប្រញាយ កាន់ដៃគ្នារណោង។ នាងទេវីនៅផ្ទះតែងខ្លួនស្អាតបាត។ ធីតាចង់ទៅទទួលប្ដី តែនាងពុំហ៊ានទៅទេ ព្រោះខ្លាចក្រែងគេសើចនាង ។ ស្ត្រីបារម្ភក្រែងនាងយំនៅមុខគេឯង នាំឲ្យខ្មាសគេ។ ទេ! នាងពុំទៅទេ ព្រោះប្រាំបីខែមកហើយ ពុំដឹងប្រុសប្រែប្រួលយ៉ាងណា។ បើនាង

អត្ថបទដោយ៖ មាស សុភាព

ទៅទទួលគេ ហើយស្រាប់តែគេធ្វើពុំស្គាល់នាងក៏ពុំដឹង នោះនាងមុខជាដាច់ខ្យល់ស្លាប់ភ្លាមក្នុងពេលនោះមិនខាន។ កល្យាណនឹកទៅទៀតថា បើគេស្មោះចំពោះនាង ស្រលាញ់នាងពិតៗ ប្រាកដជាគេមករកនាងហើយ ។ អាស្រ័យហេតុនេះ នាងសម្រេចថាត្រូវរង់ចាំប្តីអែផ្ទះទើបត្រូវ។ ស្រីនៅផ្ទះមែន តែនាងលួចស្តាប់សូរស្គរ និង សូរមាត់គេដែលស្រែកទ្រហឹងអឺងកង។ នាងស្រៀវក្នុងចិត្តចង់ទៅឲ្យធាប់បានឃើញមុខប្តី។ ចំណង់នេះរកទប់ស្ទើរពុំឈ្នះ។ ដើម្បីបំភ្លេចសេចក្តីទន្ទឹង នាងដើរចុះដើរឡើង តែក្នុងផ្ទះម្នាក់ឯង ក្នុងការទន្ទឹងរង់ចាំនេះ មួយនាទីយូរដូចមួយសតវត្ស។ មនុស្សម្នាក់លោតចូលតាមបង្អួចឮសូរគ្រឹប។ នាងទេវីភ្ញាក់ងាកទៅស្រាប់តែឃើញកាមាជាប្អូនមានន្ទមកដល់។ នាងភ័យតក្កមា ស្ទើរស្លុតស្មារតី។ កាមាដើរទៅរកនាងឈរជំទាញជើង ដៃទាំងពីរកាន់ដាវ ដែលហូតទុកជាស្រេច។

- ថ្ងៃនេះជាថ្ងៃចុងក្រោយបំផុតដែលខ្ញុំប្រើវិធីឃោរឃៅ...។ ខ្ញុំបាននិយាយនឹងអ្នកឲ្យមានចិត្តស្មោះស្ម័គ្រនឹងខ្ញុំ ព្រោះខ្ញុំបានស្រលាញ់អ្នកស្មើជីវិត។ ពាក្យដែលខ្ញុំនិយាយទៅអ្នកអ្នកឥតស្តាប់ខ្ញុំសោះ។ ខ្ញុំដាក់ខ្លួនរហូតដល់ទៅហ៊ានអង្វរចិត្តអ្នក ។ ឥឡូវខ្ញុំឈប់និយាយឈប់អង្វរទៀតហើយ ។ ខ្ញុំចាប់ប្រើវិធីអកុសលប្រាកដ ។ ខ្ញុំស្តាយណាស់ដោយអ្នកបង្ខំឲ្យខ្ញុំលេងវិធីដ៏លាមកនេះដែលខ្ញុំពុំចង់លេងឡើយ។ តែខ្ញុំធ្វើនេះ គឺប្រាកដធ្វើដោយចិត្តចង់ដោយចេតនា ដើម្បីលុបលាងអាម៉ាស់របស់ខ្ញុំចំពោះអ្នក ដែលខ្ញុំបានពាយលើកំណាត់ជីវិតរបស់ខ្ញុំជាមួយនឹងអ្នក ។ ថ្ងៃនេះ ជាថ្ងៃផ្តាច់ព្រាត់របស់ខ្ញុំ។

កាមានិយាយដោយពាក្យធ្ងន់ៗ ។ នាងទេវីចំហមាត់ បើកភ្នែកធំៗស្តាប់ ។ សេចក្តីភិតភ័យមួយយ៉ាងធំមកគ្របដន្តប់ដួងចិត្តនាងជាប់។ នាងយំអង្វរថា ៖

- ទេ ! លោក ៗ កុំធ្វើបាបខ្ញុំ ... ។

កាមាគំហកវិញថា៖

- ខ្ញុំធ្វើល្អណាស់ហើយជាមួយនឹងអ្នក។ អ្នកពុំព្រមយល់ ពុំព្រមធ្វើតាម ពុំព្រមជឿខ្ញុំ។ នែ ! ទេវីស្រីវរលក្ខណ៍ មើលនុ៎ះហ្ន៎ !

អត្ថបទដោយ៖ មាស សុភាព

កាមាចង្អុលទៅបង្អួចដែលចំហនៅផ្ទះធំមួយទៀត។ នាងទេវីមើលតាម ឃើញកូនស្រីរបស់នាងគេងលក់ស្កប់ស្កល់។ នាងស្ទុះក្រោក តែចុងដាវកាមាចុចជាប់ត្រង់កនាងកន្ទែងជីពចរមិនឲ្យស្រីកម្សត់ក្រោកបាន។ ដោយតឹងទ្រូងពេក ជីតាទ្រហោយំ ហើយពោលយ៉ាងរអាក់រអួលថា៖

- កូន ៗ មាសម្ដាយ កូន ! ម្ដាយនឹកកូនណាស់ កូនមកនេះមក។ កូនមកពីណាបាត់យូរម៉្លេះ ? កូននឹកម្ដាយទេ ?។ ឱ !កូនគេងលក់ទេ ? ម្ដាយស្មានតែកូនស្លាប់ទៅហើយ។ កូនទៅណាបាត់ប៉ុន្មានថ្ងៃ? កូនបានអ្វីបៅ ? លោក ! ខ្ញុំសុំកូនខ្ញុំមកវិញ។

កាមាគំហកទៀតថា៖

- នៅឲ្យស្ងៀម មើលទៅទៀតមើល!

នាងទេវីចោលភ្នែកទៅទៀត នាងស្រែកយ៉ែឡើង ដោយនាងបានឃើញមនុស្សម្នាក់មាឌធំ ចាប់លើកបីកូននាងដែលនៅក្នុងពូកឡើង។ មនុស្សមោហនេះយកចុងដាវដាក់លើកូននាងដែលដេកលក់ ហាក់បម្រុងនឹងប្រហារជីវិត។

- អែ ! ធ្វើយ៉ាងនេះស្លាប់កូនខ្ញុំហើយ។ លោកធ្វើអ្វីយ៉ាងហ្នឹង អាណិតកូនខ្ញុំទៅកុំធ្វើបាបគ្នា។ ឱ ! ស្លាប់ឥឡូវហើយ ព្រះម្ចាស់ថ្លៃអើយ ! កុំ ៗ លោកជួយខ្ញុំផង កុំៗ។

នាងទេវីញ័ររន្ធត់អស់អង្គប្រាណ។ កល្យាណបម្រះនឿលរមួលខ្លួន។ ចុងដាវធ្វើឲ្យនាងតក់ស្លុតត្រដាក់ចុងដៃ និងចុងជើង។ នាងដាក់ភ្នែកចុះ ពុំមែនកែវពុំហ៊ានមើលទេ តែស្រីរអាក្នុងចិត្តក្រៃពេក។ នាងយំព្យឃឹសៗ។ កាមាពេបមាត់និយាយថា៖

- ទេវី ! វាមិនទាន់ស្លាប់ទេ ។ ចូរអ្នកជ្រាបថា គឺខ្ញុំនេះហើយដែលបានលួចយកកូនអ្នកទៅ។
- ចាំ៎ះ ! លោក ! ឱ ! លោកយកកូនខ្ញុំទៅឬ ? ចាំ៎ះ !
- ឥឡូវនេះអ្នកចង់បានកូនអ្នកវិញទេ?
- ចាំ៎ះ លោក ចង់បាន សុំអាណិតខ្ញុំទៅ ខ្ញុំអង្វរ . . . !
- តើអ្នកស្រលាញ់កូនអ្នកទេ ?

អត្ថបទដោយ៖ មាស សុភាព

- ចា៎ះ លោក ស្រលាញ់ ហ៊ី ! ស្រលាញ់ណាស់ . . . ពេក ស្រលាញ់ផុតអស់របស់ដែលមានក្នុងលោកនេះ។
- តើអ្នកចង់ឲ្យកូនអ្នកស្លាប់ ឬ រស់ ?
- ចា៎ះ ! ចង់ឲ្យរស់!
- អើ ! បើចង់ឲ្យកូននេះរស់ ងាយណាស់ !
- ឲ្យខ្ញុំធ្វើយ៉ាងណា ? ចា៎ះ ខ្ញុំចង់ឲ្យរស់ ធ្វើយ៉ាងណាលោក ខ្ញុំធ្វើទាំងអស់។ ជម្រាបប្រសាសន៍មកខ្ញុំធ្វើ។

កាមាសើច មើលមុខកល្យាណយ៉ាងកំណាច។ បុរសបន្តវាចាទៅទៀតថា៖

- កិច្ចអ្នកត្រូវធ្វើងាយទេ។ បន្តិចទៀត ប្ដីអ្នកមុខជាមកដល់ទីនេះហើយ ។ ដើម្បីឲ្យកូនរស់ ដើម្បីឲ្យបានកូនមកដៃអ្នកវិញ ដល់ប្ដីអ្នកមក ឲ្យអ្នកនៅស្ងៀមធ្វើថ្លង់ ធ្វើដូចគ កុំនិយាយឲ្យសោះ។
- គ្រាន់តែកុំនិយាយឲ្យសោះប៉ុណ្ណោះ ឬ លោក ?
- អើ ! ទោះជាមួយមាត់ ក៏កុំនិយាយដែរ។
- ទេ ! ខ្ញុំនឹកប្ដីណាស់ ខ្ញុំសុំនិយាយរកគាត់បានបួនដប់ម៉ាត់ អាណិតខ្ញុំទៅ ខ្ញុំនឹកគាត់ណាស់។
- មិនបាន ! បើអ្នកហ៊ានតែហើបមាត់មួយម៉ាត់ កូនអ្នកមុខជាស្លាប់មិនខាន អ្នកឃើញទេខ្ញុំនៅទីនេះ បើអ្នកហ៊ាននិយាយមួយម៉ាត់ ខ្ញុំគ្រាន់តែធ្វើសញ្ញាបន្តិចទៅ អ្នកដែលកាន់កូនអ្នកនោះសម្លាប់កូនអ្នកចោលមិនខាន ។ ម៉េចអ្នកយល់ទេ ?
- ចា៎ះ ! ខ្ញុំយល់ហើយ ហ៊ី ! លោកគ្មានមេត្តាដល់ខ្ញុំសោះ ម៉េចក៏លោកមិនចង់ឲ្យខ្ញុំនិយាយនឹងប្ដីខ្ញុំ ? ខ្ញុំធ្វើដូចលោកមិនកើតទេ សូមលោកអត់ទោសចុះ ។ ឱប្ដីអើយ ! ឱកូនអើយ ! ខ្ញុំស្លាប់ហើយ។
- មើលហ្ន៎ ! ឃើញទេ ?
- អស់ ! ឱ ទេៗ កុំសម្លាប់កូនខ្ញុំ ទេ! លោកអើយ លោកអើយ ឱ!

អត្ថបទដោយ៖ មាស សុភាព

- ម៉េចធ្វើតាមខ្ញុំឬទេ ឆាប់ៗឡើង ?
- ហ៊ឹស លោកអើយ!
- ថាឲ្យភ្លាមមក !
- ចាំះ ! ខ្ញុំធ្វើតាមទាំងអស់ហើយ!
- ម៉េចអ្នកធ្វើតាមខ្ញុំទេ ? និយាយឲ្យត្រង់ទៅ!
- ចាំះ ខ្ញុំយល់ព្រមហើយលោក!
- អើ ! អ្នកត្រូវនៅឲ្យស្ងៀមមួយកន្លែងនេះ។
- ចាំះ ! ខ្ញុំធ្វើបាន . . . តែកាលណាទៅបានលោកឲ្យកូនមកខ្ញុំវិញ។
- មិនអីទេ ចាំខ្ញុំយកមកឲ្យ។
- កាលណាទៅ ទើបខ្ញុំអាចនិយាយបាន ?
- ចាំខ្ញុំជូនដំណឹងជាក្រោយ តែមិនយូរទេ មួយភ្លែតប៉ុណ្ណោះក៏បានហើយ
- ចាំះ ! ខ្ញុំត្រេកអរណាស់ ខ្ញុំមិនភ្លេចទេ ខ្ញុំធ្វើតាមលោកមិនឲ្យខុសទេ គឺនៅស្ងៀមមួយកន្លែងនេះ រួចមិននិយាយមួយម៉ាត់សោះ ។ អូ តិចលោកប្រឡំធ្វើសញ្ញាអ្វីទៅ។ គេសម្លាប់កូនខ្ញុំហើយ។
- ទេ ! ទេ ! ខ្ញុំមិនច្រលំទេ!
- អោ ! កូនកំសត់អើយ . . . ។

**(សូមរង់ចាំតាមដានភាគទី១៩ នៅសប្តាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព